តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងយុវជនក្នុងប្រទេសកម្ពុជា៖




## ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

របាយការណ៍សង្ខេប ២០២០

# អំពីអង្គការតម្លាភាពកម្ពុជា

អង្គការតម្លាភាពកម្ពុជាគឺជាសាខាក្នុងប្រទេសមួយដែលមានការទទួលស្គាល់ពេញលេញរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការកាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញជាច្រើនដែលបានប្តេជ្ញាធ្វើឱ្យសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់ពីពេលនោះមក អង្គការតម្លាភាពកម្ពុជា បានក្លាយជាស្ថាប័នដ៏រឹងមាំមួយ ដែលប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេស។

យើងធ្វើការជាមួយបុគ្គល និងស្ថាប័នគ្រប់កម្រិត ដូចជា៖ រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

អង្គការតម្លាភាពកម្ពុជា
ផ្ទះលេខ ១៣ ផ្លូវលេខ ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក, ១២០៤០៧,
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ៨៨៣ ៦៨១ / (+៨៥៥) ២៣ ៨៨៣ ៦៨២

គេហទំព័រ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្តាល៖ www.transparency.org

ប្រធានគម្រោង៖ លោកស្រី ស្តើង ភារ៉ុង កញ្ញា យ៉ាង លាភា និង លោក អ៊ឹម នរិន្ទ
អ្នកស្រាវជ្រាវ និងអ្នកនិពន្ធ៖ អ្នកស្រី Nakagawa Kasumi

២០២០ អង្គការតម្លាភាពកម្ពុជា។ ឯកសារនេះស្ថិតនៅក្រោម
អាជ្ញាប័ណ្ណ CC BY-ND 4.0 ។

# សេចក្តីបដិសេធ ទទួលខុសត្រូវ

ឯកសារនេះត្រូវបានរៀបរៀងឡើងក្រោមជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងការគាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងសហភាពអឺរ៉ុប (EU)។ រាល់ខ្លឹមសារនៅក្នុងឯកសារនេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយណាមួយឡើយ។

ស៊ុយអែត Sverige

សហភាពអឺរ៉ុប

USAID FROM THE AMERICAN PEOPLE

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះអាចសម្រេចទៅបានដោយសារតែមានកិច្ចខិតខំសហការរបស់តួអង្គជាច្រើន ជាពិសេសអ្នកដឹកនាំការស្រាវជ្រាវ និងអ្នកនិពន្ធរបស់យើង គឺលោកស្រី Nakagawa Kasumi ដែលកិច្ចខិតខំ និងជំនាញឯកទេសរបស់លោកស្រី បានផ្តល់ឱ្យអង្គការតម្លាភាពកម្ពុជានូវខ្លឹមសារស្រាវជ្រាវដែលមានគុណភាពខ្ពស់បំផុត។ បន្ថែមពីនេះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកចុះស្រាវជ្រាវតាមមូលដ្ឋាន គឺលោក លាន ឆវ័ន្ត លោក មិន ចាន់តុលា កញ្ញា សម ស៊ីសូម៉ា កញ្ញា លីម ហ្គេចហួយ លោក ម៉ុក បូដា លោក ជួប ពុទ្ធចំរើន កញ្ញា ឃុន សុខអេង និងលោក លីម តៅស៊ីន ដែលបានធ្វើកិច្ចសម្ភាសដើម្បីប្រមូលទិន្នន័យបឋមក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តគោលដៅ។ ម្យ៉ាងវិញទៀត សូមថ្លែងអំណរគុណជាពិសេសដល់លោក Richard Hocking ដែលបានចំណាយពេលវេលាក្នុងការត្រួតពិនិត្យ និងកែសម្រួលរបាយការណ៍។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ដែលភាគច្រើនជាមនុស្សវ័យក្មេង នឹងបានចូលរួមយ៉ាងសកម្មក្នុងការសិក្សានេះតាមរយៈការផ្តល់ទស្សនៈយល់ឃើញផ្ទាល់ខ្លួន ហើយនិងចែករំលែកបទពិសោធន៍ ព្រមទាំងចំណេះដឹងរបស់ពួកគេដោយសេរីស្តីពី ភាពជាអ្នកដឹកនាំរបស់យុវជន និងស្ត្រីក្នុងប្រទេសកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកចូលរួមដទៃទៀត រួមទាំងអាជ្ញាធររដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ស្ថាប័នអប់រំ អ្នកស្រាវជ្រាវ អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ បុគ្គលអន្តរភេទ និងអ្នកមិនកំណត់ភេទនិងយេនឌ័រ(LGBTIQ) ដែលមានឆន្ទៈចែករំលែកទស្សនៈយល់ឃើញផ្ទាល់ខ្លួនជាមួយក្រុមសិក្សាស្រាវជ្រាវ។ យើងខ្ញុំសូមអរគុណយ៉ាងស្មោះស្ម័គ្រចំពោះក្តីសប្បុរសរបស់ពួកគាត់ក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍ផ្ទាល់ខ្លួន ផ្តល់ធាតុចូល និងមតិយោបល់ ព្រមទាំងផ្តល់ឱកាសឱ្យក្រុមការងារបានសិក្សារៀនសូត្រផងដែរ។

សូមថ្លែងអំណរគុណជាពិសេសចំពោះគណៈគ្រប់គ្រងជាន់ខ្ពស់របស់អង្គការតម្លាភាពកម្ពុជា ដែលបានផ្តល់ឱកាសឱ្យក្រុមស្រាវជ្រាវបានធ្វើការសិក្សានេះ។ សូមថ្លែងអំណរគុណជាពិសេសចំពោះលោក ប៉ិច ពិសី នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា ចំពោះការដឹកនាំ និងការចង្អុលបង្ហាញក្នុងការសិក្សាស្រាវជ្រាវនេះ។ យើងខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី ស្តើង ភារ៉ុង ប្រធានគ្រប់គ្រងកម្មវិធី និងកញ្ញា យ៉ាង លាភា មន្ត្រីសម្របសម្រួលកម្មវិធី ដែលបានសម្របសម្រួលដំណើរការទាំងមូលនៃការស្រាវជ្រាវនេះ រួមទាំងការចង្អុលបង្ហាញលើដំណើរការស្រាវជ្រាវ និងកិច្ចខិតខំក្នុងការរៀបចំផ្នែកភ័ស្តុភារសម្រាប់ការងារចុះស្រាវជ្រាវតាមមូលដ្ឋាននៅទីតាំងផ្សេងៗជាច្រើន ក៏ដូចជាការចែករំលែកទស្សនៈ នឹងមតិយោបល់ដោយភាពកក់ក្តៅបើកចំហ និងក្នុងន័យស្ថាបនា។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក អ៊ឹម នរិន្ទ ដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវទាំងមូល រួមទាំងការសរសេរសេចក្តីព្រាងឯកសារទស្សនាទាន ការចង្អុលបង្ហាញលើដំណើរការស្រាវជ្រាវ និងការផ្តល់ធាតុចូល ព្រមទាំងការពិនិត្យជាច្រើនដងលើសេចក្តីព្រាងរបាយការណ៍បឋម និងរបាយការណ៍ចុងក្រោយ។ យើងខ្ញុំក៏សូមអរគុណចំពោះបុគ្គលិកមួយចំនួនរបស់អង្គការតម្លាភាពកម្ពុជាសម្រាប់ការចូលរួមចំណែករបស់ពួកគាត់ រួមមាន៖ លោក ទៀន សាមមើឌី មន្ត្រីសម្របសម្រួលការិយាល័យអង្គការតម្លាភាពកម្ពុជាប្រចាំខេត្តកំពត កញ្ញា ឈន រក្សា មន្ត្រីសម្របសម្រួលការិយាល័យអង្គការតម្លាភាពកម្ពុជាប្រចាំខេត្តសៀមរាប កញ្ញា ជា ស្រីពៅ មន្ត្រីសម្របសម្រួលការិយាល័យអង្គការតម្លាភាពកម្ពុជាប្រចាំខេត្តព្រៃវែង កញ្ញា អេង មួយហួង មន្ត្រីសម្របសម្រួលការិយាល័យអង្គការតម្លាភាពកម្ពុជាប្រចាំខេត្តរតនគិរី កញ្ញា នក់ ស្រីលាភ ជំនួយការការិយាល័យអង្គការតម្លាភាពកម្ពុជាប្រចាំខេត្តបាត់ដំបង កញ្ញា ងន់ សៀវម៉ី និងលោក ផាន់ រតនវិទ្យា បុគ្គលិកហាត់ការនៃអង្គការតម្លាភាពកម្ពុជា។ បន្ថែមពីនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះសមាជិកគណៈកម្មការពិគ្រោះយោបល់ដែលបានជួយធានានូវវិធីសាស្ត្រស្រាវជ្រាវ និងវិធីអនុវត្តការសិក្សានេះមានប្រសិទ្ធភាព និងសមស្រប។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះម្ចាស់ជំនួយរបស់គម្រោងនេះ គឺទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) សហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលជានិច្ចកាលតែងតែផ្តល់ការគាំទ្រចំពោះការងាររបស់យើង។

# បញ្ជីអក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| អង្គការសង្គមស៊ីវិល | (CSO) |
| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ | (CEDAW) |
| ការពិភាក្សាជាក្រុម | (FGD) |
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ | (ICCPR) |
| ការសម្ភាសស៊ីជម្រៅ | (KII) |
| អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ បុគ្គលអន្តរភេទ និងអ្នកមិនកំណត់ភេទនិងយេនឌ័រ | (LGBTIQ) |
| ក្រសួងអប់រំ យុវជន និងកីឡា | (MoEYS) |
| ក្រសួងកិច្ចការនារី | (MOWA) |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | (NSDP) |
| អង្គការមិនមែនរដ្ឋាភិបាល | (NGOs) |
| រាជរដ្ឋាភិបាលកម្ពុជា | (RGC) |
| រដ្ឋបាលថ្នាក់ក្រោមជាតិ | (SNA) |
| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | (SDG) |
| អង្គការតម្លាភាពអន្តរជាតិ | (TI) |
| សហភាពសហព័ន្ធយុវជនកម្ពុជា | (UYFC) |


USAID

# របាយការណ៍សង្ខេប

## ១. សេចក្តីផ្តើម៖ គោលបំណង វិធីសាស្ត្រស្រាវជ្រាវ និងវិសាលភាពនៃការសិក្សា

ការពង្រឹងសិទ្ធិអំណាចស្ត្រី និងយុវជនឱ្យចូលរួមក្នុងជីវភាពនយោបាយ និងសង្គមបានក្លាយជាបេសកកម្មស្នូលមួយរបស់អង្គការតម្លាភាពកម្ពុជាចាប់តាំងពីពេលអង្គការនេះកកើតឡើង។ តាមរយៈសកម្មភាពផ្សេងៗជាច្រើនដែលអង្គការតម្លាភាពកម្ពុជាបានអនុវត្តនៅទូទាំងប្រទេសកន្លងមក យើងឃើញថា ស្ត្រី និងយុវជនមានតំណាងតិចតួចណាស់ក្នុងវិស័យសាធារណៈ ជាពិសេសក្នុងតួនាទីដឹកនាំទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ គោលបំណងរួមនៃការសិក្សានេះ គឺដើម្បីកំណត់នូវឧបសគ្គ និងបញ្ហាប្រឈមសំខាន់ៗដែលស្ត្រីនិងយុវជនកម្ពុជាជួបប្រទះនៅក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។



គោលបំណងនៃការសិក្សានេះ គឺដើម្បី៖

- ចងក្រងជាឯកសារនូវការវិវឌ្ឍនានាថ្មីៗទាក់ទងនឹងតួនាទីដឹកនាំរបស់ស្ត្រី និងយុវជនក្នុងប្រទេសកម្ពុជា
- កំណត់រកវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការបង្កើតនូវបរិយាកាសអំណោយផលសម្រាប់យុវជន និងស្ត្រី ដើម្បីអាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និង
- លើកឡើងនូវអនុសាសន៍ជាក់លាក់សម្រាប់រដ្ឋាភិបាល អង្គការ/បណ្តាញសង្គមស៊ីវិល និងស្ថាប័នអប់រំ ដើម្បីអាចលើកកម្ពស់ស្ត្រី និងយុវជននៅក្នុងតួនាទីដឹកនាំប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការអនុវត្តលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរ។

ការសិក្សានេះពឹងលើវិធីសាស្ត្រប្រមូលទិន្នន័យចំនួនបី។ ទិន្នន័យបឋម (Primary data) គឺទទួលបានមកពីការសម្ភាសស៊ីជម្រៅ (KII) និងការពិភាក្សាជាក្រុម (FGDs) ចំណែកទិន្នន័យមានស្រាប់ (Secondary data) គឺទទួលបានតាមរយៈការពិនិត្យឯកសារពាក់ព័ន្ធដែលមានស្រាប់។

ការប្រមូលទិន្នន័យបឋម (ការចុះសម្ភាសតាមមូលដ្ឋាន) ត្រូវបានធ្វើឡើងចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែមករា ឆ្នាំ ២០២០ ដោយមានមនុស្សសរុបចំនួន ៥៦៩នាក់បានផ្តល់ចម្លើយ (ស្ត្រី ២៤៤នាក់ និងLGBTIQ ១០នាក់)។ ក្នុងនោះរួមមានទាំងមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិនៅរាជធានីភ្នំពេញ និងមន្ត្រីអាជ្ញាធរថ្នាក់ក្រោមជាតិនៅខេត្តចំនួន៥ គឺខេត្តរតនគិរី ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពត និងខេត្តព្រៃវែង។ បន្ថែមលើប្រជាជនទូទៅ(បុរស និងស្ត្រី) មានព្រះសង្ឃចំនួន១៦អង្គ និង LGBTIQ ចំនួន ១០នាក់ ត្រូវបានសម្ភាសដើម្បីប្រមូលទស្សនៈយល់ឃើញ និងគំនិតស៊ីជម្រៅរបស់ពួកគាត់ចំពោះតួនាទីដឹកនាំរបស់យុវជន និងស្ត្រី។

## ២. ការរកឃើញសំខាន់ៗពីការពិនិត្យឯកសារពាក់ព័ន្ធដែលមានស្រាប់

### ២.១. ឧបសគ្គចំពោះភាពជាអ្នកដឹកនាំរបស់ស្ត្រី

បទដ្ឋានសង្គមក្នុងប្រព័ន្ធដែលឱ្យតម្លៃបុរសជាធំមានការរើសអើងស្ត្រី៖ ទំនាក់ទំនងយេនឌ័រមិនស្មើភាព និងការលម្អៀងឥទ្ធិពល ដោយសារតែការកាន់អំណាច និងការគ្រប់គ្រងលើសលប់ដោយបុរស ជាហេតុនាំឱ្យមានក្តីរំពឹងថា តួនាទីដឹកនាំ គឺជាតួនាទីដែលបំពេញដោយបុរស។

បន្ទុកទ្វេដងសម្រាប់ស្ត្រី៖ ស្ត្រីនិងក្មេងស្រីត្រូវទទួលបន្ទុកធ្វើការងារផ្ទះក្នុងបរិមាណដ៏ច្រើន រួមទាំងការងារមិនទទួលបានប្រាក់កម្រៃ ដូចជាការថែទាំអ្នកជំងឺ និងកុមារ/មនុស្សចាស់។

ការទទួលបានការអប់រំនៅតែជាបញ្ហាប្រឈមសម្រាប់ស្ត្រី៖ លទ្ធភាពទទួលបានការអប់រំខ្ពស់នៅតែជាឧបសគ្គចំពោះស្ត្រីជាច្រើន ហើយបើគ្មានលទ្ធភាពចូលសាលា និងទទួលបានការអប់រំខ្ពស់ទេនោះ ស្ត្រីជាច្រើនមិនអាចទទួលបានឱកាសកាន់តួនាទីដឹកនាំឡើយ។

កង្វះការផ្តល់ឱកាសពីគណបក្សនយោបាយ៖ ការបោះឆ្នោតនៅកម្ពុជាពឹងផ្អែកលើប្រព័ន្ធបោះឆ្នោតជ្រើសរើសគណបក្សនយោបាយ ហើយគណបក្សនយោបាយភាគច្រើនពុំមានការកំណត់កូតាសម្រាប់ស្ត្រីនៅក្នុងបញ្ជីបេក្ខភាពឡើយ។

កង្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងនយោបាយ៖ ការទាមទារផ្នែកហិរញ្ញវត្ថុពីគណបក្សនយោបាយក្នុងការអនុម័តលើបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់ខ្លួនដើម្បីចូលរួមក្នុងយុទ្ធនាការបោះឆ្នោត ក៏ជាឧបសគ្គមួយសម្រាប់ស្ត្រីផងដែរ។

ឧបសគ្គលក្ខណៈស្ថាប័ន៖ មើលតាមទិដ្ឋភាពប្រវត្តិសាស្ត្រ ដំណើរការធ្វើសេចក្តីសម្រេចចិត្តតែងមើលរំលងស្ត្រី ហើយបានបង្កើតជាឧបសគ្គដែលបន្ទច់បង្អាក់ពួកគាត់ក្នុងការក្លាយជាអ្នកដឹកនាំ។

### ២.២. ឧបសគ្គចំពោះភាពជាអ្នកដឹកនាំរបស់យុវជន

សាធារណជនទូទៅមានទំនុកចិត្តតិចតួចលើសមត្ថភាពយុវជន៖ ឧបសគ្គផ្នែកប្រវត្តិសាស្ត្រ ដូចជាសាធារណជនទូទៅនៅក្នុងសហគមន៍ខ្វះទំនុកចិត្តលើសមត្ថភាពរបស់យុវជន។

ឧបសគ្គផ្នែកហិរញ្ញវត្ថុ៖ ការធ្វើចំណាកស្រុកជាញឹកញាប់របស់យុវជនដើម្បីស្វែងរកឱកាសការងារក៏អាចរារាំងការចូលរួមជាប្រព័ន្ធរបស់យុវជននៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តផងដែរ។

ឧបសគ្គលក្ខណៈស្ថាប័ន៖ ឧបសគ្គលក្ខណៈស្ថាប័នដែលយុវជនជួបប្រទះពេលពួកគេព្យាយាមចូលទៅកាន់តួនាទីដឹកនាំបណ្តាលមកពីបទដ្ឋានសង្គម និងវប្បធម៌ដែលធ្វើឱ្យការអភិវឌ្ឍសមត្ថភាពយុវជនចុះខ្សោយ។



## ៣. ការរកឃើញសំខាន់ៗពីការចុះស្រាវជ្រាវតាមមូលដ្ឋាន

ការសិក្សានេះកំណត់ឃើញឧបសគ្គចម្បងចំនួន៧ ទៅលើភាពជាអ្នកដឹកនាំរបស់ស្ត្រី ដែលត្រូវបានសង្ខេបក្នុងតារាងខាងក្រោម៖

| ឧបសគ្គ | ការបកស្រាយ |
|---|---|
| ៣.១. ឧបសគ្គចំពោះភាពជាអ្នកដឹកនាំរបស់ស្ត្រី | |
| បន្ទុកគ្រួសារ | ស្ត្រីត្រូវបានរំពឹងថា ជាអ្នកទទួលខុសត្រូវលើកិច្ចការងារផ្ទះជាច្រើន និងត្រូវផ្តល់អាទិភាពដល់បញ្ហាគ្រួសារ ដូចជាការថែទាំកូនជាដើម ដូច្នេះហើយពួកគេអាចជួបប្រទះឧបសគ្គក្នុងការរក្សាតុល្យភាពរវាងកិច្ចការគ្រួសារ និងកិច្ចការសង្គម។ |
| កង្វះការលើកទឹកចិត្ត/ការគាំទ្រ | ក្មេងស្រីជាច្រើនធំឡើងដោយពុំបានទទួលការលើកទឹកចិត្តជាវិជ្ជមាន ពីឪពុកម្តាយ ឬលោកគ្រូអ្នកគ្រូរបស់ពួកគេដើម្បីក្លាយជាអ្នកដឹកនាំ ហើយក្មេងស្រីទាំងនោះត្រូវបានរំពឹងថានឹងរៀបការ ហើយនឹងមើលថែទាំផ្ទះសំបែង។ |
| ឥទ្ធិពលរបស់បុរសលើសលប់ក្នុងវិស័យសាធារណៈ | ការធ្វើសេចក្តីសម្រេចចិត្ត ឬភាពជាអ្នកដឹកនាំនៅក្នុងវិស័យសាធារណៈត្រូវទទួលរងឥទ្ធិពលរបស់បុរសលើសលប់ ហើយវប្បធម៌នេះបានធ្វើឱ្យមានផលលំបាកសម្រាប់ស្ត្រីដើម្បីចូលរួមក្នុងវិស័យសាធារណៈ ក៏ព្រោះតែកង្វះលក្ខខ័ណ្ឌ/បរិយាកាសសមស្របសម្រាប់ពួកគាត់ដើម្បីបញ្ចេញមតិយោបល់ផ្ទាល់ខ្លួននៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ |
| ការអប់រំ/សមត្ថភាព/ទំនុកចិត្តរបស់ស្ត្រីនៅទាប | ស្ត្រីវ័យក្មេងនៅមិនទាន់អាចក្លាយជាអ្នកដឹកនាំបាន ដោយសារមានការរើសអើងលើអាយុ ឬក៏ពួកគាត់អាចនៅខ្វះទំនុកចិត្តដើម្បីចូលបំពេញតួនាទីជាអ្នកដឹកនាំ ព្រោះពួកគាត់ខ្វះបទពិសោធន៍ការងារច្បាស់លាស់។ |
| ការរើសអើងដោយបុរស និងស្ត្រីដទៃទៀត | ឥរិយាបថបុរេនិច្ច័យ និងរើសអើងពីបុរស និងស្ត្រីផ្សេងទៀត ចំពោះអ្នកដឹកនាំស្ត្រីត្រូវបានលើកឡើងថាជាឧបសគ្គផងដែរ។ លទ្ធផលពីការចុះស្រាវជ្រាវតាមមូលដ្ឋានក៏បង្ហាញដែរថា មានតែអ្នកចូលរួមសម្ភាស ៣៨%ប៉ុណ្ណោះ ដែលយល់ស្របថា ស្ត្រីអាចក្លាយជាអ្នកដឹកនាំល្អ។ |
| ផ្នត់គំនិតអប់រំមួយចំនួនក្នុងច្បាប់ស្រី | "ច្បាប់ស្រី" ត្រូវបានលើកឡើងថាជាឧបសគ្គមួយផងដែរ ហើយអ្នកចូលរួមជាច្រើនក្នុងការសិក្សានេះបានលើកឡើងនូវផ្នត់គំនិតដែលថា "ស្ត្រីគួរបែបនេះ ឬបែបនោះ" បានរឹតត្បិតសេរីភាពរបស់ស្ត្រី ហើយថែមទាំងបន្ទច់បង្អាក់ពួកគាត់ពីការចូលរួមកិច្ចការសង្គម។ |
| សុខភាព (ភាពទន់ខ្សោយផ្នែករាងកាយ និងការមានគភ៌បន្ទច់បង្អាក់ស្ត្រីពីការផ្តោតការយកចិត្តទុកដាក់លើការធ្វើសេចក្តីសម្រេចចិត្ត/ការដឹកនាំ) | ការយល់ឃើញស្រដៀងគ្នាមួយត្រូវបានរាយការណ៍ថា ស្ត្រីមានរាងកាយ "ទន់ខ្សោយ" និងមិនសមទៅនឹងកិច្ចការសង្គមឡើយ រួមទាំងការកាន់តួនាទីដឹកនាំ។ ការមានគភ៌ក៏ត្រូវបានលើកឡើងដោយអ្នកចូលរួមសម្ភាសជាច្រើនផងដែរថា វាជាឧបសគ្គរាំងស្ត្រីក្នុងការបន្តបំពេញតួនាទីរបស់ខ្លួន។ |

ដូចគ្នានឹងស្ត្រីដែរ ការសិក្សានេះរកឃើញឧបសគ្គចម្បងចំនួន៧ ដែលបន្ទចំបង្អាក់យុវជនពីការទទួលបានតួនាទីដឹកនាំ។

| ឧបសគ្គ | ការបកស្រាយ |
|---|---|
| ៣.២. ឧបសគ្គចំពោះភាពជាអ្នកដឹកនាំរបស់យុវជន[១] | |
| ការបន្ទចំបង្អាក់ពីឪពុកម្តាយ | ឪពុកម្តាយជាច្រើនបន្ទចំបង្អាក់កូនៗរបស់ខ្លួនក្នុងការចូលរួមកិច្ចការនយោបាយ រួមទាំងព្រឹត្តិការណ៍នយោបាយ ព្រោះមានការភ័យខ្លាចអំពីសន្តិសុខ/សុវត្ថិភាព ឬគិតថាកូនរបស់ពួកគាត់អាចធ្វើឱ្យប៉ះពាល់ដល់ កេរ្តិ៍ឈ្មោះគ្រួសារដោយសារទង្វើពុំគប្បីណាមួយ។ |
| ការរើសអើងទៅលើអាយុ | ដោយសារប្រព័ន្ធដែលឱ្យតម្លៃបុរសជាធំដែលបានចាក់ជ្រៅក្នុងសង្គម និងវប្បធម៌យូរមកហើយក្នុងប្រទេសកម្ពុជា មនុស្សចាស់ត្រូវទទួលការងារធ្វើសេចក្តីសម្រេចចិត្ត ហើយពួកគាត់មិនទុកចិត្តលើសមត្ថភាពរបស់យុវជននោះឡើយ។ |
| ឱកាសសម្រាប់យុវជនដើម្បីក្លាយជាអ្នកដឹកនាំនៅមានកម្រិត | វិស័យនយោបាយកម្ពុជាពោរពេញទៅដោយអ្នកនយោបាយមានបទពិសោធន៍ និងវ័យចំណាស់។ ទិដ្ឋភាពបែបនេះបានធ្វើឱ្យយុវជនយល់ឃើញថា ពុំមានឱកាសឡើយសម្រាប់ពួកគាត់ដើម្បីទទួលបានតួនាទីដឹកនាំ។ |
| ការធ្វើចំណាកស្រុកដើម្បីការងារ | យុវជនជាច្រើនត្រូវបានបង្ខំឱ្យបោះបង់ការសិក្សាដោយសារមានបញ្ហាហិរញ្ញវត្ថុក្នុងគ្រួសារ ហើយយុវជនទាំងនោះធ្វើចំណាកស្រុកស្វែងរកការងារ និងមមាញឹករកប្រាក់ចិញ្ចឹមជីវិត ថែមទាំងមិនមានពេលទំនេរដើម្បីចូលរួមបម្រើការកិច្ចការសង្គម។ |
| សេរីភាពក្នុងការបញ្ចេញមតិនៅមានកម្រិត | ក្រសួងអប់រំ យុវជន និងកីឡាដាក់បម្រាមសិស្សនិស្សិតសាកលវិទ្យាល័យក្នុងការពិភាក្សារឿងនយោបាយ ដែលបង្កជាឧបសគ្គដ៏ធំចំពោះយុវជនដើម្បីចូលរួមក្នុងវិស័យនយោបាយ។ |
| បក្ខពួកនិយម | បញ្ហាបក្ខពួកនិយមដែលមានជាប់ទាក់ទងនឹងទម្រង់ផ្សេងៗនៃអំពើពុករលួយដែលរារាំងយុវជនពីការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ |
| កង្វះជំនាញទន់ | យុវជនមានការខ្វះខាតផ្នែកបទពិសោធន៍ការងារ និងជំនាញទន់ និងមិនទាន់អាចបត់បែនដើម្បីសម្របខ្លួនទៅនឹងការងារថ្មី។ |

[១] ការឆ្លុះបញ្ចាំងវប្បធម៌នៅកម្ពុជាដែលឱ្យតម្លៃបុរសជាធំ ឧបសគ្គជាច្រើនរបស់យុវជនមានការទាក់ទងនឹងឧបសគ្គដែលស្ត្រីជួបប្រទះដែរ។

# ៤. អនុសាសន៍

## ៤.១. អនុសាសន៍៖ ភាពអ្នកដឹកនាំរបស់ស្ត្រី

### ៤.១.១. អនុសាសន៍សម្រាប់រដ្ឋាភិបាល

ដើម្បីសម្រេចបានដូចការធានាក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ដែលចែងថា ស្ត្រី និងបុរសមានភាពស្មើគ្នា (មាត្រា ៣១) និង មានសិទ្ធិស្មើគ្នាក្នុងគ្រួសារ (មាត្រា ៤៥) ត្រូវចាត់វិធានការយ៉ាងសកម្មដើម្បីកាត់បន្ថយបន្ទុករបស់ស្ត្រីពីការទទួលខុសត្រូវក្នុងគ្រួសារតាមរយៈយន្តការកិច្ចគាំពារសង្គមមួយចំនួនដូចជាការបង្កើតឱ្យមានមណ្ឌលថែទាំទារក និងកុមារតូចៗ តាមរយៈផ្តល់កញ្ចប់ថវិកាដោយឡែកដើម្បីប្រើប្រាស់សម្រាប់ជួយស្ត្រីដែលមានបំណងចង់ចូលរួមក្នុងជីវភាពនយោបាយនិងរៀបចំយុទ្ធនាការថ្នាក់ជាតិដើម្បីផ្លាស់ប្តូរផ្នត់គំនិតសង្គម និងលើកទឹកចិត្តទាំងអស់គ្នាឱ្យចេះជួយចែករំលែកការងារផ្ទះទៅវិញទៅមក។

ដើម្បីសម្របសម្រួលការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការយុទ្ធសាស្ត្រនារីរតនៈទី៥(២០១៩-២០២៣)ដែលជាគោលនយោបាយបញ្ជ្រាបយេនឌ័ររយៈពេល៥ឆ្នាំរបស់ក្រសួងកិច្ចការនារី និងគោលនយោបាយថ្នាក់ជាតិថ្មីស្តីពីសមភាពយេនឌ័រ (២០២០-២០៣០) ត្រូវផ្តល់ឱកាសកាន់តែច្រើនទៀតឱ្យស្ត្រីដើម្បីទទួលបានបទពិសោធន៍ក្នុងតួនាទីដឹកនាំដោយការផ្តល់កញ្ចប់ថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់ពួកគាត់តាមរយៈកម្មវិធីរបស់រដ្ឋាភិបាល ឬវគ្គបណ្តុះបណ្តាលពិសេសផ្សេងៗ ហើយត្រូវអនុម័តវិធានការគោលនយោបាយបន្ថែមទៀត ដើម្បីលើកកម្ពស់ស្ត្រីក្នុងតួនាទីដឹកនាំតាមរយៈការចាត់ឱ្យមានកូតាស្ត្រីកាន់តែច្រើនក្នុងបញ្ជីបេក្ខភាពឈរឈ្មោះបោះឆ្នោតសម្រាប់គណបក្សនយោបាយ ឧទាហរណ៍ការកំណត់កូតា ៣៥%។ បន្ថែមលើនេះការប្រើប្រាស់បណ្តាញប្រព័ន្ធផ្សព្វផ្សាយជាតិ (ទូរទស្សន៍ និងវិទ្យុ) និងប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី។

ដើម្បីពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG) ទី៥ ស្តីពីសមភាពយេនឌ័រ ត្រូវពិចារណាបង្កើនការផ្តល់ឱកាសឱ្យស្ត្រីនៅក្នុងដំណើរការជ្រើសរើសបុគ្គលិកដើម្បីធានាថា ឱកាសក្លាយជាអ្នកដឹកនាំ ជានិច្ចកាលត្រូវបានផ្តល់ឱ្យទៅស្ត្រីនិងពិចារណាបង្កើនថវិកាជាតិដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ដោយធានានូវការផ្តល់ណែនាំ បង្ហាត់បង្ហាញប្រកបដោយប្រសិទ្ធភាពសម្រាប់ពួកគាត់។

ដើម្បីគាំទ្រឱ្យសម្រេចបាននូវគោលដៅសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ក្នុងការបង្កើនអំណាចរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ត្រូវផ្តល់អាហារូបករណ៍បន្ថែមទៀតដល់ក្មេងស្រី និងស្ត្រីនៅតាមជនបទដើម្បីអនុញ្ញាតឱ្យពួកគេមានឱកាសទទួលបានការអប់រំខ្ពស់ រួមជាមួយការបង្កើនកន្លែងស្នាក់នៅសម្រាប់រៀនសូត្រដែលមានសុវត្ថិភាពសម្រាប់ពួកគាត់ ក៏ដូចជាការលើកទឹកចិត្តដល់ឪពុកម្តាយឱ្យបញ្ជូនកូនស្រីរបស់ខ្លួនមកសិក្សានៅកម្រិតឧត្តមសិក្សា។

ស្របជាមួយគោលការណ៍នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(CEDAW) ត្រូវចាត់វិធានការបន្ទាន់ដើម្បីផ្លាស់ប្តូរផ្នត់គំនិតចាស់គំរិលចំពោះស្ត្រីនិងអនុវត្តយុទ្ធនាការទូទាំងប្រទេសដើម្បីផ្លាស់ប្តូរទស្សនៈបែបរើសអើងរបស់សាធារណជនចំពោះតួនាទីរបស់ស្ត្រី តាមរយៈការជ្រើសយកអ្នកដឹកនាំ និងបុគ្គលល្បីៗដែលជាស្ត្រីនិងគួរឱ្យគោរពនាពេលបច្ចុប្បន្ន ជាអ្នកធ្វើយុទ្ធនាការដើម្បីជំរុញទឹកចិត្តសាធារណជនឱ្យជឿថា "ស្ត្រីអាចធ្វើអ្វីក៏បាន"។

### ៤.១.២. អនុសាសន៍សម្រាប់អង្គការសង្គមស៊ីវិល

ដើម្បីកាត់បន្ថយបន្ទុកគ្រួសាររបស់ស្ត្រី ត្រូវផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបទស្សនៈយេនឌ័រសម្រាប់ស្ត្រី និងបុរស ដើម្បីផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគាត់ដែលចាត់ទុកថាការងារផ្ទះ និងការងារមិនទទួលបានប្រាក់កម្រៃជាដើមគឺជាការងាររបស់ស្ត្រីតែម្ខាងហើយឱ្យពួកគាត់មើលឃើញថាបុរសក៏អាចធ្វើការងារនេះបានផងដែរ។ បន្ថែមលើនេះ ត្រូវលើកកម្ពស់ការយល់ដឹងរបស់បុរសក្នុងសហគមន៍ឱ្យយល់ថា ទាំងស្ត្រី និងបុរសមានសមត្ថភាពដូចគ្នា ដើម្បីក្លាយជាអ្នកដឹកនាំនិងទទួលភារកិច្ចធ្វើការងារក្នុងផ្ទះ។

ដើម្បីលើកទឹកចិត្តឱ្យមានស្ត្រីកាន់តែច្រើនក្លាយជាអ្នកដឹកនាំ ត្រូវលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍តាមរយៈការរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលឱ្យបានច្រើនសម្រាប់ស្ត្រី ដើម្បីជំរុញទឹកចិត្តពួកគាត់ឱ្យក្លាយជាអ្នកដឹកនាំហើយបង្កើតវេទិកានិងបណ្តាញសម្រាប់ស្ត្រីដើម្បីចែករំលែកព័ត៌មាន និងភ្ជាប់ទំនាក់ទំនងគ្នា។

ដើម្បីផ្លាស់ប្តូរវប្បធម៌នយោបាយដែលបុរសមានឥទ្ធិពលលើសលប់ ត្រូវសកម្មក្នុងការលើកទឹកចិត្តឱ្យស្ត្រី ចូលធ្វើការនៅតាមបណ្តាអង្គការសង្គមស៊ីវិល និងបង្កើនចំនួនបុគ្គលិកស្ត្រី។ បន្ថែមលើនេះ ត្រូវធានាថានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ស្ត្រីដែលចូលរួមទាំងអស់ទទួលបានឱកាសដើម្បីចែករំលែកគំនិត និងទស្សនៈរបស់ពួកគាត់ជាជាងត្រឹមតែចូលអង្គុយ "នៅតុប្រជុំ"។

ដើម្បីជួយស្ត្រីឱ្យទទួលបានជំនាញភាពជាអ្នកដឹកនាំ និងមានទំនុកចិត្តលើខ្លួនឯង ត្រូវផ្តល់កម្មវិធីបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំបន្ថែមទៀតសម្រាប់ក្មេងស្រី និងស្ត្រី ហើយបង្កើតកម្មវិធីតម្រង់ទិសដើម្បីជំរុញទំនុកចិត្តរបស់ស្ត្រីឱ្យបានកាន់តែច្រើន ថែមទាំងសម្របសម្រួលឱ្យមានការចងក្រងបណ្តាញស្ត្រីនៅកម្រិតផ្សេងៗក្នុងសង្គមតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។

ដើម្បីលុបបំបាត់ផ្នត់គំនិតអវិជ្ជមានពាក់ព័ន្ធនឹងតួនាទីរបស់ស្ត្រីនិងដើម្បីផ្លាស់ប្តូរការយល់ឃើញខុសឆ្គងដែលថាស្ត្រីគឺជា "ភេទទន់ខ្សោយ" ត្រូវរៀបចំសន្និសីទដោយអញ្ជើញនាយកសាលាមកពីគ្រប់កម្រិតទាំងអស់(តាំងពីថ្នាក់មុនបឋមសិក្សាដល់សាកលវិទ្យាល័យ)ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់

ស្ត្រី ធ្វើយ៉ាងណាឱ្យលោកគ្រូអ្នកគ្រូផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី។

### ៤.១.៣. អនុសាសន៍សម្រាប់សាលារៀន និងស្ថាប័នអប់រំ

ដើម្បីលើកទឹកចិត្តឱ្យមានស្ត្រីកាន់តែច្រើនក្លាយជាអ្នកដឹកនាំ ត្រូវចាត់វិធានការយ៉ាងសកម្មបន្ថែមទៀតដើម្បីលើកកម្ពស់ស្ត្រីឱ្យក្លាយជាអ្នកដឹកនាំក្នុងស្ថាប័នអប់រំក្នុងលក្ខណៈជាប្រព័ន្ធ។ ត្រូវជ្រើសរើសគ្រូបង្រៀន និងសាស្ត្រាចារ្យជាស្ត្រីឱ្យបានកាន់តែច្រើននៅក្នុងគ្រឹះស្ថានឧត្តមសិក្សាដើម្បីជាឧទាហរណ៍បង្ហាញអំពីសមត្ថភាពរបស់ស្ត្រី ដល់មនុស្សជំនាន់ក្រោយ និងបង្ហាញឱ្យឃើញថា ស្ត្រីអាចក្លាយជាអ្នកដឹកនាំក្នុងផ្នែកអប់រំបានផងដែរ។

ដើម្បីផ្លាស់ប្តូរវប្បធម៌នយោបាយដែលបុរសមានឥទ្ធិពលលើសលប់ ដើម្បីបង្កើតបរិយាកាសអំណោយផលចំពោះស្ត្រីកាន់តែច្រើនថែមទៀត ត្រូវសកម្មក្នុងការជ្រើសរើសសាស្ត្រាចារ្យជាស្ត្រីឱ្យកាន់តែច្រើននៅក្នុងមហាវិទ្យាល័យនីតិសាស្ត្រ ហើយម្យ៉ាងទៀតត្រូវផ្តល់ការអប់រំដែលយកចិត្តទុកដាក់ចំពោះយេនឌ័រកាន់តែច្រើនថែមទៀតសម្រាប់ក្មេងប្រុស និងក្មេងស្រីតាំងពីបឋមវ័យ។

ដើម្បីជួយស្ត្រីឱ្យទទួលបានជំនាញភាពជាអ្នកដឹកនាំ និងមានទំនុកចិត្តលើខ្លួនឯង ត្រូវផ្តល់វគ្គសិក្សាឯកទេសសម្រាប់ក្មេងស្រី និងស្ត្រីវ័យក្មេងឱ្យរៀនសូត្រអំពីភាពជាអ្នកដឹកនាំ ហើយរៀបចំសិក្ខាសាលា និងកម្មវិធីផ្សេងៗនៅក្នុងកម្មវិធីសិក្សាចាប់តាំងពីថ្នាក់បឋមកម្រិតទាបឡើងទៅដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ។

ដើម្បីលុបបំបាត់ផ្នត់គំនិតអវិជ្ជមានពាក់ព័ន្ធនឹងតួនាទីរបស់ស្ត្រី និងដើម្បីផ្លាស់ប្តូរការយល់ឃើញខុសឆ្គងដែលថាស្ត្រីគឺជា "ភេទទន់ខ្សោយ" ត្រូវអប់រំទាំងក្មេងប្រុស និងក្មេងស្រីអំពីសមភាពយេនឌ័រតាមរយៈការបង្កើតកម្មវិធីសិក្សាដែលយកចិត្តទុកដាក់ចំពោះយេនឌ័រសម្រាប់គ្រប់សាលារៀនទាំងអស់ដោយប្រើប្រាស់សម្ភារៈ/ឯកសារសិក្សា ដែលសមស្របទៅតាមអាយុពួកគាត់។ ត្រូវផ្សព្វផ្សាយដល់មនុស្សពេញវ័យឱ្យគាំទ្រការផ្លាស់ប្តូរទស្សនៈខុសឆ្គងរបស់ពួកគាត់ ដើម្បីឱ្យមើលឃើញថា ទាំងក្មេងប្រុស និងក្មេងស្រីចាំបាច់ត្រូវចូលរួមចំណែកធ្វើការងារផ្ទះដូចគ្នាមិនថាការងារប្រើកម្លាំងកាយ និងកម្លាំងចិត្តនោះទេ។

ដើម្បីស្វែងយល់បន្ថែមអំពីសក្តានុពលនៃកម្មវិធីណែនាំបង្ហាត់បង្ហាញ និងតម្រង់ទិសនៅក្នុងប្រទេសកម្ពុជា ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីកំណត់រកប្រភេទកម្មវិធីតម្រង់ទិសនានាដែលត្រូវបានអនុវត្តរួចមកហើយក្នុងប្រទេសកម្ពុជា និងបង្កើតកម្មវិធីតម្រង់ទិសគំរូមួយសម្រាប់បរិបទកម្ពុជា ដោយសារការងារទាំងនេះនៅពុំទាន់មានភាពទូលំទូលាយនៅឡើយក្នុងប្រទេសកម្ពុជា។

ដើម្បីស្វែងយល់បន្ថែមអំពីភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងវិស័យឯកជន ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីកំណត់រកកត្តាអំណោយផលសម្រាប់ស្ត្រីជាពិសេសស្ត្រីវ័យក្មេងក្នុងការក្លាយជាអ្នកជំនួញស្ត្រីដែលជោគជ័យ និងផ្សព្វផ្សាយដល់សាធារណជនអំពីសមត្ថភាពរបស់ស្ត្រីក្នុងនាមជាអ្នកដឹកនាំអាជីវកម្ម។

## ៤.២. អនុសាសន៍៖ ភាពអ្នកដឹកនាំរបស់យុវជន

### ៤.២.១. អនុសាសន៍សម្រាប់រដ្ឋាភិបាល

ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយជាតិស្តីពីយុវជនរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគណៈកម្មាធិការតំណាងយុវជនមកពីមជ្ឈដ្ឋានផ្សេងៗគ្នា (ជនជាតិដើមភាគតិច យុវជនមានពិការភាព បុគ្គល LGBTIQ វ័យក្មេង) នៅគ្រប់ក្រសួងទាំងអស់ ដើម្បីឱ្យមានការចូលរួមជាប្រព័ន្ធពីយុវជននៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

ដើម្បីសម្រេចបានដូចការធានាក្នុងរដ្ឋធម្មនុញ្ញដែលថាប្រជាពលរដ្ឋគ្រប់រូបក្នុងប្រទេសកម្ពុជាមានភាពស្មើគ្នា (មាត្រា ៣១) និងគោលការណ៍មិនរើសអើងដែលមានចែងក្នុងច្បាប់អន្តរជាតិជាច្រើនដែលកម្ពុជាបានផ្តល់សច្ចាប័ន ត្រូវលើកកម្ពស់ឱ្យមានយុវជនកាន់តែច្រើនក្លាយជាអ្នកដឹកនាំតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងត្រូវសកម្មក្នុងការជ្រើសរើសនិងលើកកម្ពស់យុវជនក្នុងរចនាសម្ព័ន្ធរដ្ឋដោយផ្តល់ឱកាសកាន់តែច្រើនដល់មនុស្សវ័យក្មេងបានចូលធ្វើការ តាមរយៈសេវាណែនាំបង្ហាត់បង្ហាញ និងតម្រង់ទិសដើម្បីជួយពួកគាត់ឱ្យអភិវឌ្ឍទំនុកចិត្តលើខ្លួនឯង និងរៀនសូត្រពីអ្នកដឹកនាំដែលមានបទពិសោធន៍ និងមានវ័យច្រើនជាងខ្លួន។

ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការសន្យាដែលបានព្រមព្រៀងគ្នាជាអន្តរជាតិក្នុងការលើកកម្ពស់សេរីភាពក្នុងការបញ្ចេញមតិ ដូចជាកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR)ជាដើមត្រូវលុបបំបាត់ឧបសគ្គដែលរារាំងមនុស្សវ័យក្មេងក្នុងការបញ្ចេញទស្សនៈរបស់ពួកគាត់ទៅលើកិច្ចការនយោបាយនៅក្នុងគ្រឹះស្ថានអប់រំ និងត្រូវលើកកម្ពស់កិច្ចពិភាក្សាអំពីការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីលើកទឹកចិត្តយុវជនឱ្យចូលរួមក្នុងដំណើរការសម្រេចចិត្ត។

ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងក្នុងការពន្លឿនវិធានការប្រឆាំងអំពើពុករលួយរបស់អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវពន្លឿនដំណើរការកាត់បន្ថយអំពើពុករលួយនិងបញ្ហាបក្ខពួកនិយមដើម្បីធានាថា យុវជនគ្រប់រូប មកពីគ្រប់មជ្ឈដ្ឋានជាពិសេសយុវជនជាស្ត្រី មានឱកាសដូចគ្នា ឬស្មើភាពគ្នាក្នុងការចូលរួមបម្រើការងារនៅក្នុងស្ថាប័នរដ្ឋ។

### ៤.២.២. អនុសាសន៍សម្រាប់អង្គការសង្គមស៊ីវិល

**ដើម្បីបង្កើតឱកាសកាន់តែច្រើនសម្រាប់យុវជនដើម្បីក្លាយជាអ្នកដឹកនាំ** ត្រូវផ្តល់ឱកាសហ្វឹកហាត់ការងារបន្ថែមទៀតសម្រាប់យុវជន ជាពិសេសត្រូវផ្តោតលើស្ត្រីវ័យក្មេង ជួយពួកគាត់ឱ្យបានទទួលបទពិសោធន៍ការងារ និងបទពិសោធន៍ដឹកនាំកាន់តែច្រើន ផ្តល់វគ្គបណ្តុះបណ្តាលកាន់តែច្រើន និងរៀបចំសិក្ខាសាលាដែលមានភាពទាក់ទាញ ឬវគ្គសិក្សាខ្លីៗដោយផ្តល់អាទិភាពទៅលើតម្រូវការរបស់យុវជន។ផ្តល់ការគាំទ្រផ្នែកណែនាំបង្ហាត់បង្ហាញ និងតម្រង់ទិសជាលក្ខណៈប្រព័ន្ធដែលជាផ្នែកមួយនៃកម្មវិធីរបស់អង្គការសង្គមស៊ីវិលជាមួយយុវជន។

**ដើម្បីលុបបំបាត់ការរើសអើងទៅលើអាយុ** ត្រូវបង្កើតយុទ្ធនាការនិងព្រឹត្តិការណ៍កាន់តែច្រើនថែមទៀតដូចជាការជួបជុំនៅតាមសហគមន៍ ដើម្បីបង្កើនការយកចិត្តទុកដាក់ និងការយល់ដឹងរបស់មនុស្សចាស់អំពីសារៈសំខាន់នៃការចូលរួមរបស់យុវជនក្នុងភាពជាអ្នកដឹកនាំនិងក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជាពិសេសតាមរយៈការលើកកម្ពស់ស្ត្រីវ័យក្មេងឱ្យផ្សព្វផ្សាយដល់មនុស្សវ័យចាស់ ដើម្បីផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគាត់។

**ដើម្បីជំរុញឱកាសសិក្សារៀនសូត្រអន្តរជំនាន់** ត្រូវរៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗដោយអញ្ជើញ និងលើកទឹកចិត្តទាំងយុវជននិងមនុស្សវ័យចាស់ឱ្យចែករំលែកបញ្ហាប្រឈម បទពិសោធន៍ និងក្តីសង្ឃឹមរបស់ពួកគាត់ចំពោះអនាគតរបស់កម្ពុជា។

### ៤.២.៣. អនុសាសន៍សម្រាប់សាលារៀន និងស្ថាប័នអប់រំ

**ដើម្បីបង្កើតឱកាសកាន់តែច្រើនសម្រាប់យុវជនដើម្បីក្លាយជាអ្នកដឹកនាំ** ត្រូវបង្កើតកម្មវិធីភាពជាអ្នកដឹកនាំរបស់យុវជនក្នុងប្រព័ន្ធអប់រំដូចជាក្លឹបសិក្សា ឬសមាគមសិស្ស-និស្សិតជាដើម រៀបចំព្រឹត្តិការណ៍ ឱ្យមានភាពកាន់តែទាក់ទាញសម្រាប់យុវជនអាចអភិវឌ្ឍ និងបង្ហាញជំនាញគ្រប់គ្រង និងជំនាញរៀបចំផែនការរបស់ពួកគាត់ និងរៀបចំសកម្មភាពស្ម័គ្រចិត្តបន្ថែមទៀតដើម្បីឱ្យយុវជនអភិវឌ្ឍសមត្ថភាពរបស់ពួកគាត់ និងបានទទួលបទពិសោធន៍ការងារ។

**ដើម្បីជួយយុវជនឱ្យទទួលបានឱកាសការងារ** ត្រូវផ្តល់បរិយាកាសសិក្សា ដែលអំណោយផលសម្រាប់យុវជនទទួលបានការជំរុញទឹកចិត្តឱ្យចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាពិសេសសម្រាប់ស្ត្រីវ័យក្មេងដែលមានឱកាសតិចតួច ហើយនិងបង្កើតព្រឹត្តិការណ៍ ឬសកម្មភាពដែលកាន់តែមានភាពទាក់ទាញដោយផ្តោតទៅលើយុវជន ដើម្បីជំរុញទឹកចិត្តយុវជនកាន់តែច្រើនឱ្យក្លាយជាអ្នកដឹកនាំ ជាពិសេសស្ត្រីវ័យក្មេង។

**ដើម្បីស្វែងយល់អំពីឥទ្ធិពលរបស់មនុស្ស/ក្រុមមនុស្សផ្សេងគ្នាក្នុងសង្គមកម្ពុជា និងទម្រង់នៃការរើសអើងទៅលើយុវជន** ត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែមអំពីការចូលរួមរបស់យុវជនក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយកំណត់រកបទពិសោធន៍ជោគជ័យ និងចងក្រងករណីសិក្សារបស់បុគ្គលជាគំរូល្អៗ ជាពិសេសអ្នកដឹកនាំជាស្ត្រីវ័យក្មេងនិងធ្វើការចែករំលែកព័ត៌មានទាំងនោះនៅតាមបណ្តាប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីជំរុញទឹកចិត្តយុវជនជាច្រើនផ្សេងទៀតឱ្យក្លាយជាអ្នកដឹកនាំ។

**ដើម្បីលើកកម្ពស់ជំនាញចិញ្ចឹមបីបាច់កូនដើម្បីជំរុញឱ្យមនុស្សជំនាន់ក្រោយក្លាយជាអ្នកដឹកនាំ** ត្រូវផ្សព្វផ្សាយជូនដល់ឪពុកម្តាយសិស្សតាមទម្រង់ផ្សេងៗ ដូចជាការរៀបចំសិក្ខាសាលា និងព្រឹត្តិការណ៍នានានៅសាលារៀន ដើម្បីអញ្ជើញឪពុកម្តាយសិស្សឱ្យរៀនសូត្រអំពីជំនាញចិញ្ចឹមបីបាច់កូន របៀបដែលពួកគាត់អាចលើកទឹកចិត្តកូនឱ្យយកចិត្តទុកដាក់លើបញ្ហាសង្គម និងរបៀបធ្វើឱ្យកូនៗរបស់ខ្លួនចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការសង្គមក្នុងនាមជាអ្នកដឹកនាំវ័យក្មេង។

# សព្ទបច្ចេកទេសសំខាន់ៗ

| សព្ទ | និយមន័យ |
|---|---|
| តួនាទីដឹកនាំរបស់ស្ត្រី | យោងតាមក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី មិនមាននិយមន័យដែលមានការព្រមព្រៀងគ្នាជាសាកលស្តីពីភាពជាអ្នកដឹកនាំរបស់ស្ត្រីនោះទេ។ |
| យុវជន | យោងតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន (២០១១) "យុវជន" ត្រូវបានកំណត់និយមន័យថា ជាមនុស្សមានចន្លោះអាយុចាប់ពី ១៥-៣០ ឆ្នាំក្នុងប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាផ្នែកស្ថិតិនៅក្នុងតំបន់ទាំងមូល អង្គការសហប្រជាជាតិបានកំណត់និយមន័យ "យុវជន" ថាជាជនទាំងឡាយណាដែលមានអាយុចន្លោះពី ១៥ ដល់ ២៤ ឆ្នាំដោយមិនមានបុរេនិច្ច័យចំពោះនិយមន័យផ្តល់ដោយរដ្ឋសមាជិកដទៃទៀតនោះឡើយ។ |
| សមភាពរវាងស្ត្រី និងបុរស (សមភាពយេនឌ័រ)៖ | សមភាពយេនឌ័រសំដៅលើសិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើគ្នារបស់ស្ត្រី និងបុរស និងក្មេងស្រី និងក្មេងប្រុស។ សមភាពមិនមានន័យថា ស្ត្រី និងបុរស នឹងក្លាយជាមានភាពដូចគ្នានោះទេ ប៉ុន្តែបានន័យថា សិទ្ធិ ការទទួលខុសត្រូវ និងឱកាសរបស់ស្ត្រី និងបុរស គឺមិនពឹងអាស្រ័យថាតើពួកគេកើតមកជាប្រុស ឬស្រីនោះឡើយ។ សមភាពយេនឌ័របង្កប់អត្ថន័យថា ផលប្រយោជន៍ សេចក្តីត្រូវការ និងអាទិភាពទាំងរបស់ស្ត្រី និងបុរសត្រូវបានយកមកពិចារណា ដោយទទួលពុស្គាល់ភាពចម្រុះគ្នារបស់ក្រុមស្ត្រី និងក្រុមបុរសផ្សេងៗគ្នា។ សមភាពយេនឌ័រ គឺមិនមែនជាបញ្ហារបស់ស្ត្រីនោះទេ ប៉ុន្តែគួរពាក់ព័ន្ធ និងមានការចូលរួមយ៉ាងពេញលេញពីបុរស ក៏ដូចជាស្ត្រី។ សមភាពរវាងស្ត្រី និងបុរសត្រូវបានមើលឃើញថាជាបញ្ហាសិទ្ធិមនុស្សផង និងជាបុរេលក្ខខណ្ឌ ព្រមទាំងជាសូចនាករសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលផ្តោតលើមនុស្ស ផងដែរ។<br>(https://www.un.org/womenwatch/osagi/conceptsandefinitions.htm) |

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

អង្គការតម្លាភាពកម្ពុជា
ផ្ទះលេខ ១៣ ផ្លូវលេខ ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក, ១២១៥១,
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ៨៨៣ ៦៨១ / (+៨៥៥) ២៣ ៨៨៣ ៦៨២

គេហទំព័រ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្ដាល៖ www.transparency.org